រក្សាសិទ្ធិ © ពត៌មាន :
© ២០០៩ Project WorldReach © ២០០៩ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR ™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

002KH01A-01

អត្ថបទសិក្សា ទី ៣

"ដំណឹងល្អបំផុត"



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល

២

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

មនុស្សទាំងអស់សុទ្ធតែបានប្រព្រឹត្តអំពើបាប ហើយចាំបាច់ត្រូវកែប្រែចិត្តគំនិត

មានអ្នកទារពន្ធ និងមនុស្សបាបទាំងអស់ នាំគ្នាចូលមកជិតព្រះ-យេស៊ូស្តាប់ព្រះបន្ទូលរបស់ព្រះអង្គ ។ ពួកខាងគណៈផារីស៊ី និងពួកបណ្ឌិតខាងវិន័យរអ៊ូរទាំថា÷« មើល ! អ្នកនេះរាក់ទាក់នឹងមនុស្សបាប ព្រមទាំងបរិភោគជាមួយគេផង !» ។

ព្រះយេស៊ូមានព្រះបន្ទូលទៅគេជាប្រស្នានេះថា÷ *« ក្នុងចំណោមអ្នករាល់គ្នា ឧបមាថាមានម្នាក់មានចៀមមួយរយក្បាល បើគាត់បាត់ចៀមមួយ គាត់មុខជាទុកចៀមកៅសិបប្រាំបួនចោល នៅទីវាល ហើយទៅតាមរកចៀម ដែលបាត់នោះ រហូតទាល់តែបានឃើញវិញ »* ។

ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា÷ *« ព្រះជាម្ចាស់នៅស្ថានបរមសុខ មានអំណរសប្បាយ ដោយមានមនុស្សបាបតែម្នាក់កែប្រែចិត្តគំនិត ខ្លាំងជាងព្រះអង្គសប្បាយនឹងមនុស្សសុចរិតកៅសិបប្រាំបួននាក់ ដែលមិនត្រូវការកែប្រែចិត្តគំនិត »* ។

កំណត់ចំណាំ

© Project WorldReach © SEAN

កំណត់ចំណាំ

ព្រះយេស៊ូមានព្រះបន្ទូលទៀតថា÷ «មានបុរសមួយរូប មានកូនប្រុសពីរនាក់ ។ កូនពៅនិយាយទៅឪពុកថា"លោកឪពុក ! សូមចែកកេរ្តិ៍មតិកអោយកូនមក ។ ឪពុកក៏ចែកមតិកអោយកូន ។

ប៉ុន្មានថ្ងៃក្រោយមក កូនពៅប្រមូលទ្រព្យសម្បត្តិ រួចចាកចេញទៅស្រុកឆ្ងាយ ។ នៅស្រុកនោះ កូនពៅបានខ្ជះខ្ជាយបង្ហិនទ្រព្យសម្បត្តិរបស់ខ្លួនអស់ទៅ ។ ពេលចាយវាយទ្រព្យសម្បត្តិអស់ហើយ ជួនជាកើតទុរ្ភិក្សយ៉ាងខ្លាំងនៅក្នុងស្រុក កូនពៅនោះចាប់ផ្តើមខ្វះខ្វាត ។ គាត់ក៏ទៅស៊ីឈ្នួលអ្នកស្រុកម្នាក់ ។ គេប្រើអោយគាត់មើលជ្រូកតាមស្រែចំការ ។ គាត់ចង់ចំអែតក្រពះនឹងចំណីដែលគេដាក់អោយជ្រូកស៊ីនោះណាស់ តែគ្មានអ្នកណាឱ្យបរិភោគឡើយ ។

ពេលនោះកូនពៅភ្ញាក់ខ្លួន ហើយរិះគិតក្នុងចិត្តថា អ្នកបំរើរបស់ឪពុកអញ សុទ្ធតែមានម្ហូបអាហារបរិភោគហូរហៀរទាំងអស់គ្នា រីឯនៅទីនេះវិញ អញសឹងតែដាច់ពោះស្លាប់ ។ អញត្រូវតែវិលត្រឡប់ទៅរកឪពុកអញវិញ ហើយជំរាបគាត់ថា÷"លោកឪពុក កូនបានប្រព្រឹត្តអំពើបាបខុសនឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់

© Project WorldReach © SEAN

កូនក៏បានប្រព្រឹត្តអំពើបាបខុសនឹងលោកឪពុកដែរ ។ មិនគួរអោយលោកឪពុករាប់ខ្ញុំនេះជាកូនទៀតទេ ។ សូមលោកឪពុកចាត់ទុកកូនជាអ្នកបំរើចុះ" ។ លុះគិតដូច្នោះហើយ កូនពៅក៏វិលត្រឡប់ទៅរកឪពុកវិញ ។

កាលឪពុកឃើញកូនពីចំងាយ ។ គាត់មានចិត្តអាណិតអាសូរក្រៃលែង ក៏រត់ទៅទទួលកូន ហើយឱបថើបទៀតផង ។ កូនពៅជំរាបឪពុកថា÷ "លោកឪពុក កូនបានប្រព្រឹត្តអំពើបាបខុសនឹងព្រះហទ័យរបស់ព្រះជាម្ចាស់ កូនក៏ប្រព្រឹត្តអំពើបាបខុសនឹងលោកឪពុកដែរ ។ មិនគួរអោយលោកឪពុករាប់ខ្ញុំនេះជាកូនទៀតទេ" ។

ឪពុកប្រាប់ពួកអ្នកបំរើថា÷"ចូរទៅយកសម្លៀកបំពាក់ល្អៗបំផុតមកពាក់អោយកូនខ្ញុំជាប្រញាប់ ហើយយកចិញ្ចៀន និងស្បែកជើងមកពាក់អោយផង ។ ចូរយកកូនគោដែលយើងបានបំប៉នទុក មកកាប់ជប់លៀងអោយសប្បាយចុះ ដ្បិតកូនខ្ញុំនេះ បានស្លាប់ទៅហើយ តែឥឡូវរស់ឡើងវិញ វាវង្វេងបាត់ តែឥឡូវនេះ ខ្ញុំរកឃើញវិញហើយ" ។ គេនាំគ្នាជប់លៀងយ៉ាងសប្បាយ ។

កិច្ចការដែលត្រូវអនុវត្ត

- អធិស្ឋានទូលសូមអោយព្រះជាម្ចាស់បំពេញអ្នក ដោយព្រះ-វិញ្ញាណព្រះអង្គ ដើម្បីកែប្រែជីវិតអ្នក និងធ្វើឱ្យចិត្តគំនិតអ្នកក្លាយជាថ្មី ។
- និយាយរឿងអំពីកូនពៅដែលវង្វេងប្រាប់គ្រួសាររបស់អ្នក ។

បានសិក្សាអត្ថបទនេះ និងបានធ្វើកិច្ចការដែលត្រូវអនុវត្តរួចហើយ

_____ _____

(ថ្ងៃ ខែ) (ហត្ថលេខារបស់គ្រូបង្ហាត់)

© Project WorldReach © SEAN

នៅពេលដែលយើងទទួលព្រះយេស៊ូគ្រីស្ត ដោយជំនឿនោះ ព្រះ-
វិញ្ញាណដ៏វិសុទ្ធរបស់ព្រះជាម្ចាស់ នឹងយាងមកគង់ក្នុងចិត្តយើង ។
ព្រះអង្គនឹងជួយយើងឱ្យកែប្រែចិត្តគំនិត ។ តើអ្នកត្រូវការកែប្រែ
ជាប្រចាំដូចនេះ ក្នុងជីវិតអ្នកដែរឬទេ ?

☐ ត្រូវការ ។

☐ មិនត្រូវការទេ ។

ស្របទៅតាមព្រះគម្ពីរ ជំនឿដែលមិនបង្កើតផលផ្លែ ជាជំនឿ
ដែលគ្មានប្រយោជន៍ទាល់តែសោះ ។ តើនរណាជួយយើងអោយ
អាចកែប្រែយ៉ាងខ្លាំងដូចនេះបាន ?

ព្រះវិញ្ញាណនៃ _____។

ខ សំរាប់ទន្ទេញ

*«សូមបងប្អូនកែប្រែចិត្តគំនិត ហើយម្នាក់ៗត្រូវទទួលពិធីជ្រមុជ
ទឹកក្នុងព្រះនាមព្រះយេស៊ូគ្រីស្តទៅ ដើម្បីព្រះជាម្ចាស់លើកលែង
ទោសបងប្អូនអោយរួចពីបាប ហើយបងប្អូននឹងទទួលព្រះវិញ្ញាណ
ដ៏វិសុទ្ធ ដែលជាអំណោយទានរបស់ព្រះជាម្ចាស់ »* ។

(កិច្ចការ ២:៣៨)

កូនច្បងខឹងណាស់ មិនព្រមចូលផ្ទះទេ ឪពុកចេញមកអង្វរអោយ
ចូល ។ កូនច្បងនិយាយទៅកាន់ឪពុកថា÷"ខ្ញុំបាននៅបំរើលោក
ជាច្រើនឆ្នាំមកហើយ ខ្ញុំមិនដែលធ្វើខុសនឹងបង្គាប់របស់លោក
ត្រង់ណាឡើយ តែលោកមិនដែលអោយកូនពពែ ដើម្បីអោយ
ខ្ញុំកាប់ជប់លៀងជាមួយមិត្តភក្តិទាល់តែសោះ សូម្បីតែមួយ ក៏មិន
ដែលផង ។ ពេលកូនលោកត្រឡប់មកវិញ លោកបានកាប់កូន
គោបំប៉នទទួលវា ។ មើល៍វានេះ បានបំផ្លាញទ្រព្យសម្បត្តិលោក
ទាំងអស់ជាមួយស្រីញី" ។

ឪពុកនិយាយទៅកូនថា÷"កូនអើយ ឯងនៅជាមួយឪពុកជានិច្ច
រហូតណាកូន អ្វីៗទាំងអស់ដែលជារបស់ឪពុក ក៏ជារបស់កូន
ដែរ ។ យើងត្រូវតែសប្បាយរីករាយ ដ្បិតប្អូនរបស់ឯងដែលបាន
ស្លាប់ទៅនោះ ឥឡូវនេះរស់ឡើងវិញហើយ ។ វាបានវង្វេងបាត់
តែឥឡូវនេះ យើងរកឃើញវិញហើយ" » ។ (លូកា ១៥:១-៤,
លូកា ១៥:៧, លូកា ១៥:១១-២៤, លូកា ១៥:២៨-៣២) ។

តើកូនពៅធ្វើខុសអ្វី ?

សូមគូសសញ្ញា «✓» នៅក្នុងប្រអប់ «☐» ត្រង់ចំលើយដែល
ត្រឹមត្រូវ ។

តើបន្ទាប់មក វាដឹងកំហុសរបស់ខ្លួនដែរឬទេ ?

☐ ដឹង ។

☐ មិនដឹងទេ ។

កូនប្រុសពៅនោះបានកែប្រែចិត្តគំនិតពីអំពើបាប ។ តើអ្នកគិតថា មនុស្សទាំងអស់មានបាបដែរឬទេ ?

☐ មាន ។

☐ មិនមានទេ ។

កូនពៅតំណាងមនុស្សមានបាប ដែលបានកែប្រែចិត្តគំនិតដោយស្មោះ ។ តើឪពុកតំណាងនរណា ?

_____

ឪពុកតំណាងព្រះជាម្ចាស់ ។ តើឪពុករបស់គាត់លើកលែងទោសអោយគាត់ដែរឬទេ ?

☐ លើកលែង ។

☐ មិនលើកលែងទេ ។

បើសិនជាអ្នកពិតជាកែប្រែចិត្តគំនិតមែន តើព្រះបិតារបស់អ្នកដែលគង់នៅស្ថានបរមសុខ នឹងលើកលែងទោសអោយអ្នកដែរឬទេ ?

☐ លើកលែង ។

☐ មិនលើកលែងទេ ។

កូនច្បងតំណាងមនុស្សដែលប្រកាន់សាសនា ដែលមើលស្រាលចំពោះពួកអ្នកជឿថ្មី ។ ពួកអ្នកទាំងនេះគិតថា មានតែពួកគេទេដែលអាចទទួលព្រះគុណសន្តោសរបស់ព្រះជាម្ចាស់បាន ។ ប៉ុន្តែព្រះយេស៊ូមានបន្ទូលថា នឹងមានអំណរនៅក្នុងស្ថានបរមសុខ បើសិនជាមានមនុស្សបាបម្នាក់កែប្រែចិត្តគំនិត ។

តើព្រះជាម្ចាស់នឹងសប្បាយព្រះទ័យ ដោយសារអ្នកនៅពេលណា ? _____

ដើម្បីសង្គ្រោះយើង តើព្រះអម្ចាស់យេស៊ូធ្វើដូចម្តេច ?

_____

_____